*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

**សាលាដំបូងរាជធានីភ្នំពេញ**

សាលក្រមលេខ ១១២៥ "ស"

ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ១៣១៤

ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ប្រាំបួនគត់ នៅសាលសវនាការលេខ៤ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៣១៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

### <u>ចៅក្រមជំនុំជម្រះ</u>

លោក **ឆាម ច័ន្ទពិសិដ្ឋ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### <u>ក្រឡាបញ្ជីសវនាការ</u>

លោក **គុំ សុធី** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ ជ ភេទ ប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិ ខ្មែរ អាសយដ្ឋាន ខេត្តកំពត។

-អ្នកតំណាងដោយអាណត្តិលោកមេធាវី **ចាន់ ណា**។

-ចុងចម្លើយឈ្មោះ ច ភេទ ប្រុស អាយុ ៥៩ ឆ្នាំ ជនជាតិ ខ្មែរ អាសយដ្ឋាន រាជធានីភ្នំពេញ។

### <u>អង្គហេតុ និងចំណុចវិវាទ</u>

<u>១-ខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ</u>

ក-ទទួលស្គាល់ដើមចោទឈ្មោះ ជ ជាម្ចាស់កម្មសិទ្ធិករលើដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ។

ខ-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច បេគល់អចលនវត្ថុជាដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ទៅដើមចោទឈ្មោះ ជ ។

គ-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុជាដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ទៅដើមចោទឈ្មោះ ជ ។

២-<u>ការពន្យល់ត្រួសៗអំពីរឿងក្ដី</u>

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ឈ្មោះ ●៣ បានទិញដីមួយកន្លែង ទំហំ ១៦០ ម៉ែត្រការ៉េ ស្ថិតនៅ រាជធានីភ្នំពេញ ពីឈ្មោះ ●៤ តាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់អភិបាលខណ្ឌ

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ ●៣ បានផ្ទេរដីនេះឱ្យចុងចម្លើយឈ្មោះ ច នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ចុងចម្លើយឈ្មោះ ច បានលក់ដីខាងលើឱ្យដើមចោទឈ្មោះ ដ ហើយឈ្មោះ ដ បានគ្រប់គ្រងកាន់កាប់ជាប់រហូតដល់សព្វថ្ងៃ។

**៣-<u>អង្គហេតុដែលអះអាងដោយដើមចោទ</u>**

-លោកមេធាវី **ចាន់ ណរា** មេធាវីតំណាងឱ្យដើមចោទ បានថ្លែងការណ៍ថា ខ្លួនប្តឹងសុំឱ្យទទួលស្គាល់ដើមចោទឈ្មោះ ដ ជាម្ចាស់កម្មសិទ្ធិករលើដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ , បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ប្រគល់អចលនវត្ថុជាដីទំហំ ១៦០ ម៉ែត្រការ៉េ ស្ថិតនៅ រាជធានីភ្នំពេញ ឱ្យទៅដើមចោទឈ្មោះ ដ និងបង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុជាដីទំហំ ១៦០ ម៉ែត្រការ៉េ ស្ថិតនៅ រាជធានីភ្នំពេញ ឱ្យទៅដើមចោទឈ្មោះ ដ ដោយសំអាងហេតុថា ដីមួយកន្លែងនេះកូនក្តីខ្លួនបានទិញពីចុងចម្លើយឈ្មោះ ច តាមកិច្ចសន្យាទិញលក់ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ហើយកូនក្តីខ្លួនបានគ្រប់គ្រងកាន់កាប់ជាប់រហូតដល់សព្វថ្ងៃ។

**៤-<u>អង្គហេតុដែលអះអាងដោយចុងចម្លើយ</u>**

-ចុងចម្លើយឈ្មោះ ច បានថ្លែងការណ៍ថា កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ខ្លួនបានលក់ដីមួយកន្លែងទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់ នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់អភិបាលខណ្ឌ ឱ្យទៅដើមចោទឈ្មោះ ដ ពិតប្រាកដមែន។

ក្នុងរឿងនេះខ្លួនយល់ព្រមតាមខ្លឹមសារ នៃកម្មវត្ថុបណ្តឹងទាមទាររបស់ដើមចោទទាំងស្រុង។

## សំអាងហេតុ

-ផ្អែកតាមលទ្ធផល នៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងយល់ឃើញថា ៖

១-តាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់អភិបាលខណ្ឌ បញ្ជាក់បានថា ដីមួយកន្លែងទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់ឈ្មោះ ●៣ ។

២-តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ បញ្ជាក់បានថា ឈ្មោះ ●៣ បានផ្ទេរសិទ្ធិឱ្យចុងចម្លើយ ឈ្មោះ ច មានសិទ្ធិចាត់ចែងដីខាងលើ។

៣-តាមកិច្ចសន្យាទិញលក់ដីចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ បញ្ជាក់បានថា ចុងចម្លើយបានលក់ដីមួយកន្លែងទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានី

*កំណត់សំគាល់៖ សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

ភ្នំពេញ មានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់អភិបាលខណ្ឌ ឱ្យដើមចោទឈ្មោះ ជ ។

៤-ដើមចោទប្តឹងសុំឱ្យទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិករលើដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ , បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ប្រគល់អចលនវត្ថុ និងធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុខាងលើឱ្យខ្លួន ហើយចុងចម្លើយបានយល់ព្រមតាមការទាមទាររបស់ដើមចោទ ហេតុនេះតុលាការគប្បីសម្រេចតាមការព្រមព្រៀងនេះ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ តាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១/-ទទួលស្គាល់ដើមចោទឈ្មោះ ជ ជាម្ចាស់កម្មសិទ្ធិករលើដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ។

២/-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ប្រគល់អចលនវត្ថុដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ទៅដើមចោទឈ្មោះ ជ ។

៣/-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដីទំហំ ១៦០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងឈ្មោះ ●១ ខាងកើតទល់នឹង ●២ ខាងលិចទល់នឹង ●២ ស្ថិតនៅ រាជធានីភ្នំពេញ ទៅដើមចោទឈ្មោះ ជ ។

៤/-ឱ្យចុងចម្លើយឈ្មោះ ច ទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

-សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩។

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា ឆាម ច័ន្ទពិសិដ្ឋ**

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

ឆាម ច័ន្ទពិសិដ្ឋ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១៣កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩
**ក្រឡាបញ្ជី**

ភុំ សុភី